**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

ទីក្រុងស្អាត ត្រូវផ្តើមចេញពីយើងទាំងអស់គ្នា

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
លេខៈ ០០៩ សជណ គជវទ

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែពិសាខ ឆ្នាំច នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំកិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ" ក្នុងសេវាសាធារណៈរបស់ក្រុង/ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត លើកទី២ ឆ្នាំ២០១៨

ដើម្បីទទួលបានលទ្ធផលវាយតម្លៃសម្រាប់ចលនាប្រឡងប្រណាំង **"បដិសណ្ឋារកិច្ចល្អ"** ក្នុងសេវាសាធារណៈ **របស់ក្រុង/ខណ្ឌបេក្ខភាព**ដែលមានលក្ខណៈត្រឹមត្រូវ និងមានតម្លាភាព ប្រសិទ្ធភាពខ្ពស់ សំដៅចូលរួមគាំទ្រចលនាប្រឡងប្រណាំងទីក្រុងស្អាត គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត សូមជូនដំណឹងដល់ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ដែលជាសមាជិកនៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតមេត្តាផ្តល់កិច្ចសហការ និងអនុញ្ញាតអគ្គលេខាធិការដ្ឋាន គ.ជ.វ.ទ សហការជាមួយក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានី-ខេត្ត ក្នុងវាយតម្លៃ **"បដិសណ្ឋារកិច្ចល្អក្នុងសេវាសាធារណៈរបស់ក្រុង/ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត"** លើកទី២ ឆ្នាំ២០១៨។ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ស្នើឱ្យត្រៀមលក្ខណៈដោយត្រូវរៀបចំកិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ចលនាប្រឡងប្រណាំង **"បដិសណ្ឋារកិច្ចល្អក្នុងសេវាសាធារណៈរបស់ក្រុង/ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត" ឆ្នាំ២០១៨** នៅតាមរាជធានី-ខេត្ត ដូចខាងក្រោមៈ

I. **អំពីរបៀបរៀបចំប្រជុំ**

❖ កិច្ចប្រជុំត្រូវរៀបចំជាកិច្ចប្រជុំ**ទ្វេភាគី** (ត្រឹមកម្រិតជំនាញ) ក្រោមអធិបតីភាព ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារចុះវាយតម្លៃទីក្រុងស្អាត និងប្រតិភូនៃអគ្គលេខាធិការដ្ឋាន គ.ជ.វ.ទ.

❖ អភិបាលក្រុង/ខណ្ឌបេក្ខភាពត្រូវធ្វើបទបង្ហាញអំពី "ការផ្តល់សេវាសាធារណៈរបស់ក្រុង/ខណ្ឌ និងមន្ទីរអង្គភាពពាក់ព័ន្ធ" **រយៈពេល ៤៥ នាទី**។ បទបង្ហាញផ្តោតសំខាន់លើ**ប្រភេទសេវាតម្លៃ រយៈពេល ទីតាំង និងមន្ទីរអង្គភាពទទួលខុសត្រូវផ្តល់សេវា**ដែលផ្តល់ជូនប្រជាពលរដ្ឋ**នៅតាមមន្ទីរ អង្គភាពទាំង៨** រួមមានៈ មន្ទីរទេសចរណ៍ មន្ទីរបរិស្ថាន មន្ទីររៀបចំដែនដីនគរូបនីយកម្មនិងសំណង់ មន្ទីរសាធារណៈការ និងដឹកជញ្ជូន មន្ទីរសុខាភិបាល មន្ទីរពាណិជ្ជកម្ម(កាំកុងត្រូល) ស្នងការដ្ឋាននគរបាល និងច្រកចេញចូលតែមួយ។

❖ អភិបាលក្រុង/ខណ្ឌបេក្ខភាពត្រូវត្រៀមរៀបចំឯកសារអំពីតារាង**ប្រភេទសេវា តម្លៃ រយៈពេល ទីតាំង និងមន្ទីរអង្គភាពទទួលខុសត្រូវផ្តល់សេវា** (ដែលមាននៅក្នុងក្រុង/ខណ្ឌបេក្ខភាព)ជាផ្លូវការ ០១ ច្បាប់ជូនប្រតិភូគ.ជ.វ.ទ. ជា Hard Copy និង ជា Soft Copy។

II. **ពីសមាសភាពកិច្ចប្រជុំ**

❖ សមាសភាពក្នុងកិច្ចប្រជុំដែលត្រូវមានៈ

- ភាគីបេក្ខភាព
  - ឯកឧត្តម លោកជំទាវប្រធានក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានី-ខេត្ត
  - សមាជិកក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានី-ខេត្ត

- តំណាងបេក្ខភាពនៃចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អ" រួមមានៈ
    1) មន្ទីរទេសចរណ៍
    2) មន្ទីរបរិស្ថាន
    3) មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់
    4) មន្ទីរសាធារណៈការ និងដឹកជញ្ជូន
    5) មន្ទីរសុខាភិបាល
    6) មន្ទីរពាណិជ្ជកម្ម (កាំកុងត្រូល)
    7) ស្នងការដ្ឋាននគរបាល
    8) ច្រកចេញ-ចូលតែមួយ

- ភាគីប្រតិភូ គ.ជ.វ.ទ.
  - តំណាងអគ្គលេខាធិការដ្ឋាន គ.ជ.វ.ទ.
  - តំណាងក្រុមការងារវាយតម្លៃបដិសណ្ឋារកិច្ចល្អ
  - មន្ត្រីកត់ត្រា និងធ្វើរបាយការណ៍

## III. អំពីកម្មវិធីកិច្ចប្រជុំ និងកម្មវិធីចុះពិនិត្យទីតាំង

❖ **កម្មវិធីកិច្ចប្រជុំ**

- បទបង្ហាញរបស់ក្រុមការងារវាយតម្លៃអំពី "ស្តង់ដាបដិសណ្ឋារកិច្ចល្អក្នុងសេវាសាធារណៈរបស់ក្រុង/ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត"
- ការចូលរួមមតិរបស់មន្ទីរ និងអង្គភាពបេក្ខភាពនៃចលនាប្រឡងប្រណាំង
- មតិបូកសរុបដោយប្រធានប្រតិភូ គ.ជ.វ.ទ.

❖ **កម្មវិធីចុះពិនិត្យទីតាំង**

- ចុះពិនិត្យទីតាំងតាមមន្ទីរ អង្គភាពទាំង០៨ ក្នុងរាជធានី-ខេត្តរួមមានៈ មន្ទីរទេសចរណ៍ មន្ទីរបរិស្ថាន មន្ទីររៀបចំដែនដីនគរូបនីយកម្មនិងសំណង់ មន្ទីរសាធារណៈការ និងដឹកជញ្ជូន មន្ទីរសុខាភិបាល មន្ទីរពាណិជ្ជកម្ម(កាំកុងត្រូល) ស្នងការដ្ឋាននគរបាល និងច្រកចេញចូលតែមួយ។

***សំគាល់៖*** **សម្រាប់កម្មវិធីចុះពិនិត្យទីតាំងជាក់ស្តែង** នេះក្រុមការងារវាយតម្លៃបដិសណ្ឋារកិច្ចល្អនៃអគ្គលេខាធិការដ្ឋាន គ.ជ.វ.ទ. នឹងមានសំណួរសាកសួរបន្ថែមអំពីការផ្តល់សេវាទាំងគុណភាព និងបរិមាណ និងព័ត៌មាននានាបន្ថែមទៀត ស្របតាមស្តង់ដាបដិសណ្ឋារកិច្ចល្អក្នុងសេវាសាធារណៈរបស់ក្រុង/ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត។ ទន្ទឹមនឹងនេះ ក៏មានការស្រង់មតិយោបល់របស់ប្រជាពលរដ្ឋដែលទទួលសេវាពីក្រុង/ខណ្ឌ (ច្រកចេញ-ចូលតែមួយ) ព្រមទាំងមន្ទីរអង្គភាពនីមួយៗទៀតផង។

## IV. អំពីកាលបរិច្ឆេទ

❖ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតនឹងចុះត្រួតពិនិត្យ **និងវាយតម្លៃសម្រាប់ចលនាប្រឡងប្រណាំង "បដិសណ្ឋារកិច្ចល្អក្នុងសេវាសាធារណៈរបស់ក្រុង/ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត" លើកទី២ ឆ្នាំ២០១៨**នៅតាមរាជធានី-ខេត្ត **ចាប់ពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨** នេះតទៅ។

❖ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតសូមរក្សាសិទ្ធជូនដំណឹងដល់បេក្ខភាពអំពីកាលបរិច្ឆេទចុះត្រួតពិនិត្យផ្ទាល់ដល់ទីតាំងមុន ៣ថ្ងៃ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ លោក-លោកស្រី** ជ្រាបជាព័ត៌មាន និងអនុវត្តសេចក្តីជូនដំណឹងខាងលើតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក-លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

***<u>ចម្លងជូន៖</u>***

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សមាជិក នៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
  *"ដើម្បីជូនជ្រាប"*
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត
  *"ដើម្បីសហការអនុវត្ត"*
- អភិបាលក្រុង-ខណ្ឌទាំងអស់
  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ